# វិធីដាំខ្នុរ



## ១. ការជ្រើសរើសពូជ

- គួរជ្រើសរើសពូជខ្នុរបំបៅ ពីព្រោះវាមាន ផ្លែសុទ្ធល្អ និងឆាប់បានផ្លែ។
- រើសយកពូជខ្នុរមានខ្លែបច្រើន សាច់ក្រាស់។

## ២. ការរៀបចំរណ្តៅ:

- ត្រូវជីករណ្តៅ ៨តឹកបួនជ្រុង និង ជំរៅ ៨តឹក។





- រោយកំបោរស និងថ្នាំកណ្តៀរ (FURADAN) ប្រមាណ២ស្លាបព្រាបាយក្នុងរណ្តៅ។
- ត្រូវដាក់ផេះ ឬ អង្កាម, កំប្លោក, ចំបើង ពុកៗ អាចម៍គោមាន់-ជ្រូកមួយស្រទាប់ កំរាស់ ១តឹក រួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះរហូតទាល់តែពេញ ហើយកំពុង ពីមាត់រណ្តៅ។
- ត្រូវទុករណ្តៅរៀបចំហើយក្នុងរយៈពេល ២ទៅ ៣អាទិត្យ។





- ចំងាយពីរណ្តៅមួយទៅរណ្តៅមួយទៀត មាន ប្រវែង ៨ ម៉ែត្រ។

## ៣. ការដាំ:

- កូនខ្នុរត្រូវផ្សាំទុក រយៈពេល១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹកកូនខ្នុរ២ថ្ងៃមុនដាំ។



- មុនដាំត្រូវជញ្ជូនកូន ដាក់ក្បែររណ្តៅ។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- ដាំកូនខ្នុរក្នុងរណ្តៅ រួចកប់ក្នុងដីដោយរក្សាថង់ រុំបំបៅនៅលើដីប្រហែល១ធ្នាប់ដៃ។
- លប់ដីដោយសង្កត់ថ្នមៗរួចយកមែកឈើដោតក្បែររណ្តៅចងទប់ជាមួយកូនខ្នុរ។

## ៤. ការថែទាំ និងដាក់ជី:

- កាត់ថង់រុំបំបៅចេញ ក្រោយដាំបាន ១ខែ។
- ខែវស្សារត្រូវពូនគល់ការពារទឹកលិច។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើ ជី ១៥-១៥-១៥ (៣ខាំ) លាយជាមួយជី អាចម៍



គោ, មាន់,ជ្រូក,(៣បង្គី)អង្កាម, ចំបើងរួចកាយកប់ក្នុងដីធ្វើ ជាកំពែង។

- ប្រសិនបើកូនខ្នុរមានសត្វល្អិតស៊ីត្រួយ ត្រូវប្រើថ្នាំសំលាប់សត្វល្អិត ឬ ថ្នាំ S85 Carbaryl (កាបារីល) សំរាប់ជំនួយស្លឹក និងដើមលូតលាស់ល្អ។

## ៥. ការស្រោចទឹក:

- កូនខ្នុរអាយុតិចជាង១ឆ្នាំ ត្រូវស្រោចទឹក២ដងក្នុង១អាទិត្យនៅរដូវប្រាំង។
- យើងត្រូវស្រោចទឹក១ដងក្នុង១អាទិត្យនៅពេលវាកំពុងផ្កាដើម្បីការពារជ្រុះក្តិប។

## ៦. ការកាត់តែងមែក:

- ត្រូវកាត់ត្រួយចុងចេញនៅឆ្នាំទីមួយ



កាត់តែងមែកតាមប្រព័ន្ធ ១-៣-៦-១៨

- ត្រូវកាត់មែកមិនសូវល្អចេញ រៀងរាល់ឆ្នាំដោយទុកតាមប្រព័ន្ធ ១-៣-៦-១៨ (ដើម១-មែកធំ៣-ខ្នែងធំ៦ និងខ្នែង ត្រួយ១៨) បើអាចធ្វើបានជាការល្អ។

## ៧. ការប្រមូលផល:

- មិនត្រូវបេះផ្លែខ្នុរទំលាក់លើដី។ គួរឡើងបេះនិងដាក់ក្នុងសង្រែកបង្ហូតចុះក្រោម។
- បើអាចធ្វើបាន គួរកាត់ផ្លែខ្នុរឲ្យមានជាប់ទងជាការប្រសើរ។




## ឯកសារពិគ្រោះ៖

- Traing module on fruit tree production, 2013 (គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ នៅខេត្តតំបន់ពាយព្យ)
- បទពិសោធន៍កសិករ ជា ធារិទ្ធ ដាំឈើហូបផ្លែ, 2012 (ក្បែរស្ពានទឹកវិល ខណ្ឌសៀមរាប ក្រុងសៀមរាប)



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:

លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧




ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# បទពិសោធន៍ជោគជ័យ ក្នុងការដាំខ្នុរ របស់កសិករគំរូ




សហការផលិតដោយ៖

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប

ឆ្នាំ២០១៣